# សេចក្តីថ្លែងការណ៍រួម

កិច្ចប្រជុំមិត្តរបស់អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានធ្វើឡើងនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ ២០១០ ។ កិច្ចប្រជុំនេះបានប្រព្រឹត្តឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តមបណ្ឌិត **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាទីក្រុងភ្នំពេញ។ តំណាងជាង ២២ប្រទេស ហើយនឹងសហគមន៍អឺរ៉ុបដោយរួមទាំងឯកអគ្គរដ្ឋទូតមកពី ១៣ប្រទេស ក៏ដូចជា ឯកឧត្តម Clint Williamson អ្នកជំនាញការពិសេសរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកកិច្ចការអង្គជុំនំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏បានចូលរួមផងដែរ។

ឯកឧត្តម **សុខ អាន** បានថ្លែងពីការគាំទ្ររបស់រាជរដ្ឋាភិបាលចំពោះ**អ.វ.ត.ក** ហើយឯកឧត្តមបានជំរុញឲ្យតំណាងប្រទេសទាំងអស់ដែលបានចូលរួមបន្ថែមការគាំទ្ររបស់ពួកគេចំពោះតុលាការនេះ។ ឯកឧត្តម **ច័ន្ទ តានី** រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី និងឯកត្តម Clint Willamson បានជម្រាបជូនឯកអគ្គរដ្ឋទូតទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំអំពីសមិទ្ធផលជាច្រើនដែល **អ.វ.ត.ក** សំរេចបានរួមមានការប្រកាសសាលក្រមទាក់ទងនឹងសំណុំរឿង ០០១ នាពេលថ្មីៗនេះ និងដីកាសន្និដ្ឋានចុងក្រោយនៃសំណុំរឿង០០២។ ឯកឧត្តម **ច័ន្ទ តានី** និងឯកឧត្តម Clint Williamson បានគូសបញ្ជាក់ថា តុលាការនេះមានឥទ្ធិពលធំធេងណាស់សំរាប់កម្ពុជាទាក់ទងនឹងអតីតកាលដែលប្រទេសនេះបានឆ្លងកាត់ ក៏ដូចជាតួនាទីដ៏សំខាន់របស់ **អ.វ.ត.ក** សំរាប់ការផ្ទេរបច្ចេកវិទ្យា ជំនាញ និងបច្ចេកទេសផ្សេងៗទៀតសំរាប់ការអភិវឌ្ឍន៍វិស័យច្បាប់ជាតិនាពេលអនាគត។

កិច្ចប្រជុំដែលបានចូលរួមដោយឯកឧត្តមបណ្ឌិត **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងជាន់ខ្ពស់របស់ អគ្គលេខាធិការអង្គការសហប្រជាជាតិ ក៏ដូចជាឯកអគ្គរដ្ឋទូតនៃបណ្តាប្រទេសជាច្រើនបានបញ្ជាក់យ៉ាងច្បាស់ពីដៃគូរសហប្រតិបត្តិការណ៍ដ៏រឹងមាំរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិហើយនិងសហគមន៍អន្តរជាតិនានាដែលមានទំនាក់ទំនងជាមួយ**អ.វ.ត.ក** ដែលកិច្ចសហប្រតិបត្តិការណ៍នេះជាកិច្ចសហប្រតិបត្តិការណ៍ដ៏សំខាន់នៅពេលដែលតុលាការកំពុងធ្វើដំណើរឆ្ពោះទៅមុខជាមួយនឹងកិច្ចការដ៏មានសារៈប្រយោជន៍នេះ។